ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ
លេខ ....២៧៣....អស/អដ.ភ

ភ្នំពេញ . ថ្ងៃទី៣០ ខែ តុលា ឆ្នាំ២០០៧

# សេចក្ដីណែនាំ
## ស្ដីពី
## វិធីកែតម្រូវឯកសារផ្គូវការ និង Digital
## ( សំរាប់នីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ )

ឯកសារទាក់ទងនឹងសិទ្ធិលើដីធ្លី ( អចលនវត្ថុ ) ជាឯកសារប្រវត្តិសាស្ត្រ និងគតិយុត្ត ដែលទាមទារត្រូវមានគុណភាពខ្ពស់ ទាំងរូបភាព និង ខ្លឹមសារ ហើយដែលត្រូវធានាដោយស្ថាប័នជំនាញរបស់រដ្ឋដែលទទួលបន្ទុកកិច្ចការនេះ ។

ដោយសង្កេតឃើញ រយៈកាលកន្លងមក ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធនៅមានកំហុសផ្នែកបច្ចេកទេសក្នុងការកំណត់អត្តសញ្ញាណក្បាលដី ដោយព្រំប្រទល់រដ្ឋបាលមិនទាន់បានកំណត់ច្បាស់លាស់ ព្រំដីសាធារណៈមិនទាន់ត្រូវបានកំណត់ ម្ចាស់ដីខ្លះមិនបានចូលរួមពិនិត្យទិន្នន័យពេលបិទផ្សាយជាសាធារណៈ និង កង្វះការត្រួតពិនិត្យម៉ត់ចត់ពេលបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ និងពេលបោះពុម្ពប័ណ្ណចេញ បណ្ដាលឱ្យក្បាលដីខ្លះខុសទីតាំងពិតប្រាកដ ក្បាលដីខ្លះត្រួតលើគ្នាទាំងមូល ឬ ចំណែកខ្លះ ក្បាលដីខ្លះខុសទំហំ ក្បាលដីខ្លះត្រូវបានកត់ត្រាទំហំខុសគ្នាក្នុងសៀវភៅគោលបញ្ជីដីធ្លី និងក្នុងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ករណីខ្លះទៀត វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុត្រូវបាត់មុនពេលចែកជូនម្ចាស់ដី ។ ជារឿយៗ ក្រោយពេលចែកប័ណ្ណរួច តែងតែមានការតវ៉ាពីសាមីម្ចាស់នៃក្បាលដីទាំងអស់នោះ ធ្វើឱ្យមន្ត្រីជំនាញស្មុគស្មាញក្នុងការដោះស្រាយ ។

ដើម្បីដោះស្រាយកង្វះខាតដូចបានពោលខាងលើ អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ សូមធ្វើការណែនាំដូចតទៅ :

**១. កំហុសធាក់ទងនឹងអត្តសញ្ញាណនៃក្បាលដី :**

មានន័យថា ការកំណត់ក្បាលដីមួយខុសពីទីតាំងពិតប្រាកដនៃក្បាលដីនោះ ដូច្នេះក្បាលដីមួយត្រូវស្ថិតនៅលើទីតាំងនៃក្បាលដីមួយទៀត ឬក្បាលដីមួយត្រួតលើក្បាលដីមួយទៀត ឬ ក្បាលដីពីរមានមួយចំណែកត្រួត